# គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖

## ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ"

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា

# ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ
# ស្តីពី
# "ការការពារ ការគោរព និងដំណោះស្រាយ"

## គោលការណ៍ទូទៅ

គោលការណ៍ណែនាំទាំងនេះមានមូលដ្ឋានលើការទទួលស្គាល់ថា៖

(ក) រដ្ឋមានកាតព្វកិច្ចស្រាប់ក្នុងការគោរព ការពារ និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា

(ខ) សហគ្រាសពាណិជ្ជកម្ម ដែលមានតួនាទីជាអង្គភាពឯកទេសក្នុងសង្គម បំពេញមុខងារឯកទេស តម្រូវឲ្យអនុវត្តស្របតាមច្បាប់ជាធរមាន និងគោរពសិទ្ធិមនុស្ស

(គ) សេចក្តីត្រូវការឲ្យសិទ្ធិ និងកាតព្វកិច្ច មានព្រមគ្នាជាមួយនឹងការដោះស្រាយដ៏សមស្រប និងមានប្រសិទ្ធិភាព នៅពេលមានការរំលោភបំពាន។

[៣]ការបកប្រែជាភាសាខ្មែរនៃគោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្សនេះមិនបានបញ្ចូលសេចក្តីអត្ថាធិប្បាយ

គោលការណ៍ណែនាំទាំងនេះ ត្រូវយកទៅអនុវត្តនៅគ្រប់រដ្ឋ និងសហគ្រាសពាណិជ្ជកម្មទាំងអស់ ទាំងសាជីវកម្មពហុជាតិ និងសហគ្រាសផ្សេងៗទៀត ដោយមិនគិតពី ទំហំ វិស័យ ទីតាំង ប្រភេទ ម្ចាស់កម្មសិទ្ធិ និងរចនាសម្ព័ន្ធឡើយ។

គោលការណ៍ណែនាំទាំងនេះគួរត្រូវបានយល់ដឹងថា ជាគោលការណ៍មានលក្ខណៈជាក់ស្តែងទាំងស្រុង និងគួរតែត្រូវបានអាន ទោះជាដោយឯកឯងក្តី និងជារួមក្តី ដោយយល់ពីគោលបំណងនៃការពង្រឹងបទដ្ឋាននានា និងការអនុវត្តន៍ទាក់ទងនឹងធុរកិច្ចនិងសិទ្ធិមនុស្សរបស់គោលការណ៍ទាំងនេះ ដើម្បីជាប្រយោជន៍ឈានទៅសម្រេចបានលទ្ធផលជាក់ស្តែងសម្រាប់បុគ្គល និងសហគមន៍នានាដែលរងការប៉ះពាល់ ហើយអាស្រ័យហេតុនេះ វានឹងរួមចំណែកផងដែរដល់សកលភាវូនីយកម្មប្រកបដោយនិរន្តរភាពខាងសង្គម។

គ្មានចំណុចណាមួយក្នុងគោលការណ៍ណែនាំនេះ ត្រូវបានយល់ថា ជាការបង្កើតកាតព្វកិច្ចថ្មីក្រោមច្បាប់អន្តរជាតិនោះទេ ឬជាការកំហិត ឬធ្វើឲ្យចុះខ្សោយដល់កាតព្វកិច្ចតាមច្បាប់ ដែលរដ្ឋបានប្រកាន់យក ឬស្ថិតក្រោមច្បាប់អន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សនោះទេ។

គោលការណ៍ណែនាំទាំងនេះ គួរតែត្រូវបានអនុវត្តដោយគ្មានការរើសអើងដោយមានការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិ និងសេចក្តីត្រូវការ ព្រមទាំងឧបសគ្គដែលប្រឈមដោយបុគ្គល ក្រុម ឬក្រុមប្រជាពលរដ្ឋដែលមានកំរិតហានិភ័យខ្ពស់ក្នុងការក្លាយខ្លួនទៅជាជនងាយរងគ្រោះ ឬជនត្រូវគេផាត់ចេញ និងដោយមានការគិតគូរដ៏ត្រឹមត្រូវដល់ហានិភ័យផ្សេងៗគ្នាដែលស្ត្រី និងបុរសអាចនឹងប្រឈម។

# I. រដ្ឋមានភារកិច្ចការពារសិទ្ធិមនុស្ស

## ក. គោលការណ៍ជាមូលដ្ឋាន

១. រដ្ឋត្រូវតែការពារប្រឆាំងនឹង ការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្ត ដោយភាគីទីបី រាប់បញ្ចូលទាំងសហគ្រាសពាណិជ្ជកម្មនៅក្នុង ដែនដី និង/ឬ ដែនសមត្ថកិច្ចរបស់ខ្លួន។ កិច្ចការនេះតំរូវឲ្យរដ្ឋ ចាត់វិធានការសមស្របនានា ដើម្បីបង្ការ ស៊ើបអង្កេត ដាក់ទណ្ឌកម្ម និងដោះស្រាយចំពោះការរំលោភបែបនេះ តាមរយៈ គោលនយោបាយ ច្បាប់ បទបញ្ញា និងការជំនុំជម្រះតាមផ្លូវ តុលាការ ប្រកបដោយប្រសិទ្ធិភាព។

២. រដ្ឋគួរកំណត់ការរំពឹងទុកឲ្យជាក់លាក់ថា សហគ្រាសពាណិជ្ជកម្មទាំងអស់ ដែលមានទីតាំងនៅក្នុងដែនដី និង/ឬ ដែនសមត្ថកិច្ចរបស់ខ្លួន គោរពសិទ្ធិមនុស្សនៅក្នុងគ្រប់ប្រតិបត្តិការទាំង អស់របស់ពួកគេ។

## ខ. គោលការណ៍ប្រតិបត្តិការ

### *មុខងារទូទៅរបស់រដ្ឋក្នុងការបង្កើតច្បាប់ និងគោលនយោបាយ*

៣. ដើម្បីបំពេញភារកិច្ចការពាររបស់ខ្លួន រដ្ឋគួរតែៈ

(ក) អនុវត្តច្បាប់នានាដែលមានគោលបំណង ឬមានអនុភាព តំរូវឲ្យសហគ្រាសពាណិជ្ជកម្មនានា គោរពសិទ្ធិមនុស្ស និងធ្វើការវាយតំលៃតាមកាលកំណត់នូវភាពគ្រប់គ្រាន់នៃ

ច្បាប់ទាំងនោះព្រមទាំងដោះស្រាយចំពោះបញ្ហាចន្លោះប្រហោងណាមួយរបស់ច្បាប់

(ខ) ធានាថាច្បាប់ និងគោលនយោបាយផ្សេងៗ ដែលគ្រប់គ្រងការបង្កើត និងការប្រព្រឹត្តទៅនៃសហគ្រាសពាណិជ្ជកម្មនានា ដូចជាច្បាប់សាជីវកម្មពុំបង្កការរឹតត្បិត ប៉ុន្តែផ្តល់លទ្ធភាពដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស

(គ) ផ្តល់ការណែនាំដ៏មានប្រសិទ្ធិភាពដល់សហគ្រាសពាណិជ្ជកម្មនានាអំពីរបៀបគោរពសិទ្ធិមនុស្សនៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់របស់ពួកគេ

(ឃ) លើកទឹកចិត្ត និងប្រសិនបើសមស្រប តំរូវឲ្យសហគ្រាសពាណិជ្ជកម្មនានាប្រាស្រ័យទាក់ទងអំពីរបៀបដែលពួកគេដោះស្រាយលើផលប៉ះពាល់ខាងសិទ្ធិមនុស្សនានា។

## សហគ្រាសរដ្ឋ

៤. រដ្ឋនានា គួរចាត់វិធានការបន្ថែម ដើម្បីការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស ដោយសហគ្រាសពាណិជ្ជកម្ម ដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬគ្រប់គ្រងដោយរដ្ឋ ឬដែលទទួលការគាំទ្រ និងសេវាជាសារវន្តពីទីភ្នាក់ងារនានារបស់រដ្ឋ ដូចជា ក្រុមហ៊ុនធានារ៉ាប់រងការវិនិយោគ និងក្រុមហ៊ុន ឬទីភ្នាក់ងារធានារ៉ាប់រងការវិនិយោគផ្លូវការនានា ដោយរួមបញ្ចូល ប្រសិនបើសមស្រប នូវការតំរូវឲ្យធ្វើការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស។

៥. រដ្ឋគួរតែពិនិត្យមើលឲ្យគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន នៅពេលដែលពួកគេចុះកិច្ចសន្យា

ជាមួយ ឬធ្វើច្បាប់សម្រាប់សហគ្រាសពាណិជ្ជកម្ម ក្នុងការផ្តល់សេវានានា ដែលអាចប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមនុស្ស ។

៦. រដ្ឋគួរតែជំរុញសហគ្រាសពាណិជ្ជកម្មនានា ដែលខ្លួនធ្វើពាណិជ្ជកម្មជាមួយ ឲ្យគោរពសិទ្ធិមនុស្ស។

## គាំទ្រដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្សនៅក្នុងតំបន់នានាដែលមានវិវាទ

៧. ដោយសារតែហានិភ័យនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមានកំរិតខ្ពស់នៅក្នុងតំបន់នានាដែលមានវិវាទ រដ្ឋគួរតែជួយធានាថាសហគ្រាសពាណិជ្ជកម្មនានា ដែលធ្វើប្រតិបត្តិការនៅក្នុងបរិបទទាំងនោះ មិនពាក់ព័ន្ធនឹងការរំលោភបែបនោះ រួមមាន៖

(ក) ចូលរួមជាមួយសហគ្រាសពាណិជ្ជកម្ម តាំងពីដំណាក់កាលដំបូងបំផុត តាមតែអាចធ្វើទៅបាន ដើម្បីជួយពួកគេក្នុងការកំណត់ បង្ការ និងកាត់បន្ថយហានិភ័យទាក់ទងនឹងសិទ្ធិមនុស្ស ដោយសារសកម្មភាពរបស់ពួកគេ និងទំនាក់ទំនងធុរកិច្ច

(ខ) ផ្តល់ជំនួយគ្រប់គ្រាន់ ដល់សហគ្រាសពាណិជ្ជកម្ម ក្នុងការវាយតំលៃ និងដោះស្រាយចំពោះហានិភ័យកំរិតខ្ពស់នៃការរំលោភបំពាន ដោយត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះ ការរំលោភបំពានខាងផ្លូវភេទ និងការរំលោភផ្អែកលើយេនឌ័រ

(គ) បដិសេធមិនផ្តល់ការគាំទ្រ និងសេវាសាធារណៈនានាចំពោះសហគ្រាសពាណិជ្ជកម្មដែលមានជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងបដិសេធមិនធ្វើសហ

ប្រតិបត្តិការនៅក្នុងការដោះស្រាយស្ថានការណ៍នោះ

(ឃ) ធានាថា គោលនយោបាយ ច្បាប់ បទបញ្ញា និងវិធានការអនុវត្តន៍នាពេលបច្ចុប្បន្នរបស់ពួកគេ មានប្រសិទ្ធិភាពក្នុងការដោះស្រាយហានិភ័យ នៃការជាប់ពាក់ព័ន្ធរបស់ធុរកិច្ចនៅក្នុងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។

## ធានាគោលនយោបាយមានភាពស៊ីសង្វាក់គ្នា

៨. រដ្ឋគួរតែធានាថា អង្គភាព និង ទីភ្នាក់ងាររបស់រដ្ឋាភិបាល និងស្ថាប័នរដ្ឋនានា ដែលមានសមត្ថកិច្ចលើការអនុវត្តន៍របស់ធុរកិច្ច មានការយល់ដឹង និងប្រកាន់តាមកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរពសិទ្ធិមនុស្ស នៅពេលដែលបំពេញអាណត្តិរៀងៗខ្លួនរបស់ពួកគេ ដោយរួមបញ្ចូលទាំងការផ្តល់ដល់ពួកគេនូវព័ត៌មាន ការបណ្តុះបណ្តាល និងការគាំទ្រដែលពាក់ព័ន្ធនានា។

៩. រដ្ឋគួរតែរក្សាបរិយាកាសគោលនយោបាយក្នុងស្រុកគ្រប់គ្រាន់ដើម្បីបំពេញ តាមកាតព្វកិច្ចសិទ្ធិមនុស្សនៅពេលដែលអនុវត្តទៅតាមទិសដៅនូវគោលនយោបាយ ទាក់ទងនឹងធុរកិច្ចជាមួយរដ្ឋ ឬសហគ្រាសពាណិជ្ជកម្មផ្សេងៗ ឧទាហរណ៍ តាមរយៈសន្ធិសញ្ញា ឬកិច្ចសន្យាវិនិយោគនានា។

១០. នៅពេលចូលជាសមាជិកនៃស្ថាប័នពហុភាគីដែលដោះស្រាយបញ្ហាទាក់ទងនឹងធុរកិច្ច រដ្ឋគួរតែ៖

(ក) ស្វះស្វែងធានាថា ស្ថាប័នទាំងនោះមិនរិតត្បិតលទ្ធភាពនៃរដ្ឋជាសមាជិករបស់ខ្លួន ក្នុងការបំពេញភារកិច្ច

ការពារ និងមិនរារាំងសហគ្រាសពាណិជ្ជកម្មនានា ពីការគោរពសិទ្ធិមនុស្ស

(ខ) លើកទឹកចិត្តស្ថាប័នទាំងនោះ នៅក្នុងវង្វង់អាណត្តិ និងសមត្ថភាពរៀងៗខ្លួនរបស់ពួកគេ ឲ្យជំរុញដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស និងប្រសិនបើមានការស្នើសុំជួយដល់រដ្ឋក្នុងការបំពេញភារកិច្ចការពារប្រឆាំងការរំលោភសិទ្ធិមនុស្សរបស់សហគ្រាសពាណិជ្ជកម្ម រួមបញ្ចូលទាំងតាមរយៈ ជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងលើកកំពស់ការយល់ដឹង

(គ) ទាញចេញពីគោលការណ៍ណែនាំទាំងនេះ លើកស្ទួយការយល់ដឹងទាំងអស់គ្នា និងលើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការគ្រប់គ្រងធុរកិច្ច និងការប្រឈមខាងសិទ្ធិមនុស្ស។

## II. ទំនួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស

### ក. គោលការណ៍ជាមូលដ្ឋាន

១១. សហគ្រាសពាណិជ្ជកម្ម គួរតែគោរពសិទ្ធិមនុស្ស។ នេះមានន័យថា ពួកគេគួរតែជៀសវាងការបំពានលើសិទ្ធិមនុស្សរបស់អ្នកដទៃ និងគួរតែដោះស្រាយការប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរដែលពួកគេមានការពាក់ព័ន្ធ។

១២. ទំនួលខុសត្រូវរបស់សហគ្រាសពាណិជ្ជកម្ម ក្នុងការគោរពសិទ្ធិមនុស្ស សំដៅលើសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់

ជាអន្តរជាតិដោយត្រូវយល់ដឹងជាអប្បបរមាយ៉ាងហោចណាស់នូវសិទ្ធិនានា ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង គោលការណ៍នានា ដែលពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋាន ដូចមានចែងនៅក្នុងសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ ។

១៣. ទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សតំរូវថា សហគ្រាសពាណិជ្ជកម្ម៖

(ក) ជៀសវាងការបង្ក ឬរួមចំណែកធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស តាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ និងដោះស្រាយការប៉ះពាល់ទាំងនោះ នៅពេលដែលវាកើតឡើង

(ខ) ស្វះស្វែងបង្ការ ឬកាត់បន្ថយការប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស ដែលទាក់ទងដោយផ្ទាល់នឹងប្រតិបត្តិការ ផលិតផល ឬសេវារបស់ពួកគេ ឬដោយទំនាក់ទំនងខាងធុរកិច្ចរបស់ពួកគេ ទោះបីជាពួកគេពុំបានរួមចំណែកក្នុងការប៉ះពាល់ទាំងនោះក្តី។

១៤. ទំនួលខុសត្រូវនៃសហគ្រាសពាណិជ្ជកម្ម ក្នុងការគោរពសិទ្ធិមនុស្ស អនុវត្ត ចំពោះគ្រប់សហគ្រាសទាំងអស់ ដោយមិនគិតពីទំហំ វិស័យ បរិបទប្រតិបត្តិការ កម្មសិទ្ធ និងរចនាសម្ព័ន្ធរបស់ពួកគេ។ ទោះជាដូច្នោះក៏ដោយ វិសាលភាព និងភាពស្មុគស្មាញនៃវិធីសាស្ត្រដែលសហគ្រាសនានាប្រើប្រាស់ ដើម្បីបំពេញការទទួលខុសត្រូវនោះអាចមានភាពខុសៗគ្នា អាស្រ័យទៅតាមកត្តាទំហំ វិស័យ បរិបទ ប្រតិបត្តិការ កម្មសិទ្ធ និងរចនា

សម្ព័ន្ធនៃសហគ្រាសពាណិជ្ជកម្ម ព្រមទាំងជាមួយភាពធ្ងន់ធ្ងរនៃការប៉ះពាល់សិទ្ធិមនុស្សរបស់សហគ្រាសនោះ។

១៥. ដើម្បីបំពេញតាមទំនួលខុសត្រូវគោរពសិទ្ធិមនុស្សរបស់ខ្លួន សហគ្រាសពាណិជ្ជកម្ម គួររៀបចំបង្កើតគោលនយោបាយ និងដំណើរការប្រតិបត្តិការសមស្របទៅតាមទំហំ និងកាលៈទេសៈរបស់ខ្លួនដែលរួមមាន៖

(ក) ការប្តេជ្ញាចិត្តខាងគោលនយោបាយក្នុងការបំពេញទំនួលខុសត្រូវ គោរពសិទ្ធិមនុស្សរបស់ពួកគេ

(ខ) ដំណើរការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស ដើម្បីកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀបដែលពួកគេដោះស្រាយរាល់ការប៉ះពាល់នានារបស់ខ្លួនលើសិទ្ធិមនុស្ស

(គ) ដំណើរការផ្តល់លទ្ធភាពដល់ការដោះស្រាយចំពោះការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលពួកគេបង្ក ឬដែលពួកគេបានរួមចំណែក។

## ខ. គោលការណ៍ប្រតិបត្តិការ

### ការប្តេជ្ញាចិត្តខាងគោលនយោបាយ

១៦. ជាមូលដ្ឋានសម្រាប់ប្រកាន់ខ្ជាប់ទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សរបស់ខ្លួន សហគ្រាសពាណិជ្ជកម្មគួរតែបង្ហាញនូវការប្តេជ្ញារបស់ខ្លួន ក្នុងការបំពេញតាមទំនួលខុសត្រូវនេះ តាមរយៈសេចក្តីថ្លែងការណ៍នៃគោលនយោបាយដែល៖

(ក) ត្រូវបានឯកភាពដោយថ្នាក់ដឹកនាំកំរិតខ្ពស់បំផុតនៃសហគ្រាសពាណិជ្ជកម្ម

(ខ) ត្រូវបានជូនដំណឹងដោយអ្នកជំនាញការផ្ទៃក្នុង និង/ឬពីខាងក្រៅ ដែលពាក់ព័ន្ធនានា

(គ) ចែងអំពីការរំពឹងទុកនៃការគោរពសិទ្ធិមនុស្សរបស់សហគ្រាសសម្រាប់បុគ្គលិក ដៃគូធុរកិច្ច និងភាគីទីបីផ្សេងៗទៀតដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ប្រតិបត្តិការផលិតផល ឬសេវារបស់ខ្លួន

(ឃ) អាចរកបានជាសាធារណៈ និងត្រូវបានផ្សព្វផ្សាយទាំងខាងក្នុង និងខាងក្រៅទៅដល់បុគ្គលិក ដៃគូធុរកិច្ច និងភាគីទីបីដែលពាក់ព័ន្ធទាំងអស់

(ង) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការ ដែលចាំបាច់ដើម្បីបញ្ជ្រាបសេចក្តីថ្លែងការណ៍នោះនៅទូទាំងសហគ្រាសពាណិជ្ជកម្ម។

## ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស

១៧. ដើម្បីកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀប ដែលពួកគេដោះស្រាយចំពោះការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មទាំងអស់ គួរតែធ្វើការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស។ ដំណើរការនោះគួរតែ រួមបញ្ចូលការវាយតំលៃអំពីផលប៉ះពាល់ជាក់ស្តែង និងជាសក្តានុពលលើសិទ្ធិមនុស្ស ការបូកបញ្ចូលនិងចាត់វិធានការចំពោះការរកឃើញ ការតាមដានការឆ្លើយតប និងការប្រាស្រ័យទាក់ទងលើរបៀបដោះស្រាយការប៉ះពាល់ទាំងនោះ។ ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិ

មនុស្ស៖

(ក) គួរតែគ្របដណ្ដប់លើការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលសហគ្រាសពាណិជ្ជកម្មអាចបង្ក ឬរួមចំណែកបង្ក តាមរយៈសកម្មភាពផ្ទាល់របស់ខ្លួន ឬអាចមានជាប់ទាក់ទង ដោយផ្ទាល់នឹងប្រតិបត្តិការ ផលិតផល ឬសេវារបស់ខ្លួន ឬ ដោយទំនាក់ទំនងខាងធុរកិច្ចរបស់ខ្លួន

(ខ) នឹងមានលក្ខណៈខុសៗគ្នា អាស្រ័យលើភាពស្មុគស្មាញទៅ តាមទំហំ នៃសហគ្រាសពាណិជ្ជកម្មនោះ ហានិភ័យនៃការ ប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ព្រមទាំងបរិយាកាស និង បរិបទនៃប្រតិបត្តិការរបស់សហគ្រាសនោះ

(គ) គួរតែធ្វើជាបន្តបន្ទាប់ ដោយទទួលស្គាល់ថា ហានិភ័យខាង សិទ្ធិមនុស្ស អាចប្រែប្រួលពីពេលមួយទៅពេលមួយ ខណៈ ដែលប្រតិបត្តិការ និងបរិបទប្រតិបត្តិការរបស់សហគ្រាស ពាណិជ្ជកម្មចេះតែវិវត្តទៅមុខ។

១៨. ដើម្បីវាស់ស្ទង់ហានិភ័យខាងសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្ម គួរតែកំណត់ និងវាយតំលៃលើការប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជា សក្តានុពលណាមួយលើសិទ្ធិមនុស្ស ដែលពួកគេអាចជាប់ពាក់ព័ន្ធ តាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ ឬជាលទ្ធផលនៃទំនាក់ទំនង ខាងធុរកិច្ចរបស់ពួកគេ។ ដំណើរការនេះគួរតែ៖

(ក) យកចេញមកពីជំនាញសិទ្ធិមនុស្សមាននៅផ្ទៃក្នុង និង/ឬ មកពីខាងក្រៅដែលឯករាជ្យ

(ខ) រួមបញ្ចូលការពិគ្រោះយោបល់ដ៏មានអត្ថន័យ ជាមួយក្រុម ដែលរងការប៉ះពាល់ជាសក្តានុពល និងអ្នកពាក់ព័ន្ធផ្សេងៗ

ទៀត សមស្របទៅតាមទំហំនៃសហគ្រាសពាណិជ្ជកម្មនោះ ព្រមទាំងតាមបរិបទ និងបរិយាកាសនៃប្រតិបត្តិការរបស់ខ្លួន។

១៩. ដើម្បីបង្ការ និងកាត់បន្ថយការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានា គួរតែធ្វើសមាហរណកម្មទៅក្នុងគ្រប់មុខងារ និងដំណើរការផ្ទៃក្នុងដែលពាក់ព័ន្ធទាំងអស់នូវការរកឃើញនានាបានមកពីការវាយតំលៃផលប៉ះពាល់របស់ខ្លួន និងចាត់វិធានការសមស្រប។

(ក) ការធ្វើសមាហរណកម្មដ៏មានប្រសិទ្ធិភាពតំរូវថា៖

(i) ទំនួលខុសត្រូវសម្រាប់ដោះស្រាយការប៉ះពាល់ត្រូវផ្តល់ភារកិច្ចទៅឲ្យកំរិត និងមុខងារប្រតិបត្តិការដែលសមស្រប នៅក្នុងសហគ្រាសពាណិជ្ជកម្មនោះ

(ii) ការធ្វើការសម្រេចចិត្តផ្ទៃក្នុង ការបែងចែកថវិកា និងដំណើរការត្រួតពិនិត្យមើល ផ្តល់លទ្ធភាពឲ្យមានការឆ្លើយតបដ៏មានប្រសិទ្ធិភាពចំពោះការប៉ះពាល់ទាំងអស់នោះ។

(ខ) ចំណាត់ការសមស្របនឹងមានភាពខុសៗគ្នាទៅតាម៖

(i) ថាតើសហគ្រាសពាណិជ្ជកម្មបង្ក ឬរួមចំណែកបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរ ឬថាតើសហគ្រាសពាណិជ្ជកម្មមានជាប់ពាក់ព័ន្ធទាំងស្រុង ដោយសារតែការប៉ះពាល់នោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ប្រតិបត្តិការផលិតផល ឬសេវារបស់ខ្លួន ឬដោយទំនាក់ទំនងខាង

ធុរកិច្ចរបស់ខ្លួន

(ii) វិសាលភាពនៃឥទ្ធិពលរបស់សហគ្រាសក្នុងការដោះស្រាយការប៉ះពាល់ធ្ងន់ធ្ងរ។

២០. ដើម្បីបញ្ជាក់ថា តើការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្សកំពុងត្រូវបានដោះស្រាយ សហគ្រាសពាណិជ្ជកម្មនានាគួរតែតាមដានប្រសិទ្ធិភាពនៃការឆ្លើយតបរបស់ពួកគេ។ ការតាមដានគួរតែៈ

(ក) ផ្អែកលើរង្វាស់ប្រកបដោយបរិមាណ និងគុណភាពសមស្រប

(ខ) ផ្អែកលើប្រតិកម្មដែលបានមកពីទាំងប្រភពផ្ទៃក្នុង និងខាងក្រៅ រួមទាំងអ្នកពាក់ព័ន្ធដែលរងការប៉ះពាល់នានាផងដែរ។

២១. ដើម្បីមានគណនេយ្យភាព ចំពោះរបៀបដែលពួកគេដោះស្រាយការប៉ះពាល់លើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានា គួរតែរៀបចំជូនដំណឹងអំពីបញ្ហានេះ ទៅខាងក្រៅ ជាពិសេសនៅពេលដែលកង្វល់នានាត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធដែលរងការប៉ះពាល់ ឬដោយតំណាងរបស់ពួកគេ។ សហគ្រាសពាណិជ្ជកម្មដែលប្រតិបត្តិការ ឬបរិបទប្រតិបត្តិការរបស់ខ្លួន បង្កហានិភ័យឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស គួរតែរាយការណ៍ជាផ្លូវការអំពីរបៀបដែលខ្លួនដោះស្រាយការប៉ះពាល់ទាំងនោះ។ នៅក្នុងគ្រប់ព្រឹត្តិការណ៍ទាំងអស់ ការជូនដំណឹងនោះគួរតែៈ

(ក) ជាទម្រង់មួយ និងមានភាពញឹកញាប់ ដែលវាឆ្លុះបញ្ចាំងអំពីការប៉ះពាល់លើសិទ្ធិមនុស្សរបស់សហគ្រាស ព្រមទាំងអាចផ្សព្វផ្សាយបានដល់អ្នកពាក់ព័ន្ធនានាដែលខ្លួនមានបំណងផ្តល់ដំណឹង

(ខ) ផ្តល់ព័ត៌មានដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីវាយតំលៃលើភាពគ្រប់គ្រាន់នៃការឆ្លើយតបរបស់សហគ្រាសនោះចំពោះការប៉ះពាល់សិទ្ធិមនុស្សដែលខ្លួនមានការពាក់ព័ន្ធ

(គ) ដូចគ្នាផងដែរ មិនត្រូវបង្កហានិភ័យដល់អ្នកពាក់ព័ន្ធដែលរងការប៉ះពាល់ បុគ្គលិក ឬដល់លក្ខខ័ណ្ឌតំរូវស្របច្បាប់នានា ខាងការសម្ងាត់របស់ពាណិជ្ជកម្មនោះទេ។

## ការដោះស្រាយ

២២. នៅពេលដែលសហគ្រាសពាណិជ្ជកម្មនានា កំណត់បានថា ពួកគេបានបង្ក ឬរួមចំណែកបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរ ពួកគេគួរតែផ្តល់ ឬធ្វើសហប្រតិបត្តិការ ស្វែងរកដំណោះស្រាយតាមរយៈដំណើរការស្របច្បាប់នានា។

## កត្តានានានៃបរិបទ

២៣. នៅក្នុងគ្រប់បរិបទទាំងអស់ សហគ្រាសពាណិជ្ជកម្មគួរតែៈ

(ក) អនុលោមតាមច្បាប់ជាធរមានទាំងអស់ និងគោរពសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅគ្រប់ទីកន្លែងដែលពួកគេធ្វើប្រតិបត្តិការ

(ខ) ស្វះស្វែងរកមធ្យោបាយដើម្បីលើកកំពស់ដល់គោលការណ៍សិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅពេលប្រឈមមុខនឹងលក្ខខ័ណ្ឌតំរូវដែលមានវិវាទគ្នា

(គ) ចាត់ទុកហានិភ័យនៃការបង្ក ឬរួមចំណែកបង្កឲ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ថាជាបញ្ហាដែលត្រូវទទួលខុសត្រូវតាមច្បាប់នៅគ្រប់ទីកន្លែងដែលពួកគេធ្វើប្រតិបត្តិការ។

២៤. នៅពេលដែលមានការចាំបាច់ ដើម្បីចាត់អាទិភាពលើចំណាត់ការនានាក្នុងការដោះស្រាយការប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជាសក្តានុពលលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានាគួរតែស្វះស្វែងបង្ការ និងកាត់បន្ថយការប៉ះពាល់នានា ដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុត ឬប្រសិនបើពន្យាពេលការឆ្លើយតប អាចនឹងបណ្តាលឲ្យការប៉ះពាល់ទាំងនោះមិនអាចដោះស្រាយបាន។

## III. ការទទួលបានការដោះស្រាយ

### ក.គោលការណ៍ជាមូលដ្ឋាន

២៥. ជាផ្នែកមួយនៃភារកិច្ចរបស់ពួកគេ ក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដែលទាក់ទងនឹងធុរកិច្ច រដ្ឋនានាត្រូវតែចាត់វិធានការសមស្រប តាមរយៈផ្លូវតុលាការ រដ្ឋបាល នីតិបញ្ញត្តិ ឬតាមមធ្យោបាយសមស្របផ្សេងៗទៀត ដើម្បីធានាថា នៅពេលដែលមានការរំលោភបែបនោះកើតឡើងនៅក្នុងដែនដី និង/ឬដែនសមត្ថកិច្ចរបស់ខ្លួន អ្នកដែលទទួលរងការប៉ះពាល់នឹងទទួលបានការដោះស្រាយ ប្រកបដោយប្រសិទ្ធិភាព។

### ខ.គោលការណ៍ប្រតិបត្តិការ

### យន្តការដោះស្រាយតាមប្រព័ន្ធតុលាការរបស់រដ្ឋ

២៦. រដ្ឋគួរតែចាត់វិធានការសមស្រប ដើម្បីធានាប្រសិទ្ធិភាពនៃយន្តការតុលាការក្នុងស្រុក នៅពេលដែលដោះស្រាយការរំលោភសិទ្ធិ

មនុស្សនានាដែលទាក់ទងនឹងធុរកិច្ច រួមទាំងការពិចារណាលើមធ្យោបាយនានា ដើម្បីកាត់បន្ថយការប្រើប្រាស់នីតិវិធីតាមផ្លូវច្បាប់ ការអនុវត្តន៍នានា និងរបាំងដែលពាក់ព័ន្ធផ្សេងៗទៀតដែលអាចនាំឲ្យរាំងស្ទះដល់ការទទួលបានការដោះស្រាយ។

## យន្តការដោះស្រាយរបស់រដ្ឋក្រៅប្រព័ន្ធតុលាការ

២៧. រដ្ឋនានាគួរតែ ផ្តល់យន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការដ៏មានប្រសិទ្ធិភាព និងសមស្រប ទន្ទឹមគ្នានឹងយន្តការតាមប្រព័ន្ធតុលាការ ដែលជាផ្នែកមួយនៃប្រព័ន្ធដោះស្រាយដ៏ទូលំទូលាយរបស់រដ្ឋ សម្រាប់ធ្វើការដោះស្រាយការរំលោភសិទ្ធិមនុស្សទាក់ទងនឹងធុរកិច្ច។

## យន្តការដោះស្រាយមិនមែនរបស់រដ្ឋ

២៨. រដ្ឋនានាគួរតែពិចារណារកមធ្យោបាយសម្រាប់សម្របសម្រួលដល់ការទទួលបាននូវយន្តការដោះស្រាយមិនមែនរបស់រដ្ឋដ៏មានប្រសិទ្ធិភាព ដើម្បីដោះស្រាយព្យសនកម្មនានាខាងសិទ្ធិមនុស្សដែលទាក់ទងនឹងធុរកិច្ច។

២៩. ដើម្បីបង្កភាពងាយស្រួលសម្រាប់ការដោះស្រាយឲ្យបានឆាប់រហ័ស និងដោយផ្ទាល់ សហគ្រាសពាណិជ្ជកម្មនានាគួរតែបង្កើតឬចូលរួមនៅក្នុងយន្តការដោះស្រាយកំរិតប្រតិបត្តិការដ៏មានប្រសិទ្ធិភាព សម្រាប់បុគ្គល និងសហគមន៍នានាដែលអាចទទួលរងការប៉ះពាល់ធ្ងន់ធ្ងរ។

៣០. ឧស្សាហកម្ម អ្នកពាក់ព័ន្ធពហុភាគី និងកិច្ចផ្តួចផ្តើមកិច្ចសហប្រតិបត្តិការផ្សេងៗទៀត ដែលធ្វើប្រតិបត្តិការផ្អែកលើការគោរពបទដ្ឋានសិទ្ធិមនុស្ស គួរតែធានាឲ្យមាននូវយន្តការដោះស្រាយប្រកបដោយប្រសិទ្ធិភាព។

## លក្ខណៈវិនិច្ឆ័យដ៏មានប្រសិទ្ធិភាពសម្រាប់យន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ

៣១. ដើម្បីធានាដល់ប្រសិទ្ធិភាពនៃយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការទាំងរបស់រដ្ឋ និងមិនមែនរបស់រដ្ឋ យន្តការទាំងនោះគួរតែ៖

(ក) ស្របច្បាប់៖ ទទួលបានទំនុកចិត្តពីក្រុមអ្នកពាក់ព័ន្ធនានា ដែលជា កម្មវត្ថុនៃយន្តការទាំងនោះ ព្រមទាំងមានគណនេយ្យភាពចំពោះការប្រព្រឹត្តដោយយុត្តិធម៌លើដំណើរការដោះស្រាយនានា

(ខ) អាចប្រើប្រាស់បាន៖ ត្រូវបានយល់ដឹងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងអស់ ដែលជាកម្មវត្ថុនៃយន្តការទាំងនោះ ព្រមទាំងផ្តល់ជំនួយឧបត្ថម្ភគ្រប់គ្រាន់ដល់អ្នក ដែលអាចប្រឈមមុខនឹងរបាំងដោយឡែកណាមួយ ដែលរារាំងមិនឲ្យពួកគេប្រើប្រាស់យន្តការទាំងនោះបាន

(គ) អាចព្យាករណ៍បាន៖ ផ្តល់នីតិវិធីច្បាស់លាស់ និងងាយស្រួលយល់ អមជាមួយនឹងតារាងពេលវេលាសម្រាប់ដំណាក់កាលដោះស្រាយនិមួយៗ ហើយពន្យល់យ៉ាងច្បាស់លាស់អំពីប្រភេទនៃដំណើរការ និងលទ្ធផលដែលមានព្រមទាំងវិធីសាស្ត្រតាមឃ្លាំមើលការអនុវត្តន៍

(ឃ) សមធម៌៖ ស្វះស្វែងធានាថា ភាគីរងគ្រោះនានាទទួលបាន ព័ត៌មាន ការប្រឹក្សា និងជំនាញការសមស្របដែលចាំបាច់ សម្រាប់ចូលរួមក្នុងដំណើរការដោះស្រាយដែលមានលក្ខណៈ យុត្តិធម៌ មានព័ត៌មានគ្រប់គ្រាន់ និងដោយការគោរព

(ង) តម្លាភាព៖ ភាគីនានានៃយន្តការនេះត្រូវទទួលបានការជូន ដំណឹង ជាប់ជានិច្ចអំពីការវិវត្តទៅមុខនៃនីតិវិធី ព្រមទាំងផ្តល់ ព័ត៌មានគ្រប់គ្រាន់អំពីការប្រព្រឹត្តទៅនៃយន្តការនេះ ដើម្បី កសាងទំនុកចិត្តលើប្រសិទ្ធិភាពនៃយន្តការ និងការពារផល ប្រយោជន៍សាធារណៈណាមួយ ដែលប្រឈមមុខនឹង ហានិភ័យ

(ច) សិទ្ធិជានិរន្តរ៍៖ ធានាថា លទ្ធផលនិងការដោះស្រាយអនុលោម តាមសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ

(ឆ) ប្រភពនៃការសិក្សាជាបន្ត៖ ស្រង់ចេញពីវិធានការពាក់ព័ន្ធ នានា កំណត់យកមេរៀន ដើម្បីធ្វើឲ្យប្រសើរឡើងដល់យន្ត ការនេះ ព្រមទាំង បង្ការវិវាទ និងព្យសនកម្មនាពេលអនាគត

**យន្តការកំរិតប្រតិបត្តិការក៏គួរតែមានលក្ខណៈដូចខាងក្រោមផងដែរ៖**

(ជ) ផ្អែកលើការចូលរួម និងការសន្ទនា៖ ពិគ្រោះយោបល់ជាមួយ ក្រុមអ្នកពាក់ព័ន្ធនានាដែលជាកម្មវត្ថុនៃយន្តការទាំងនេះ អំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការទាំងនេះ ព្រមទាំង ផ្តោតការយកចិត្តទុកដាក់លើការសន្ទនា ធ្វើជាវិធីសាស្ត្រក្នុង ការដោះស្រាយវិវាទ។